ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

**មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរពីប្រទេសម៉ាឡេស៊ី និងចិន**

------------

១- ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ម៉ាឡេស៊ី** បានដោះស្រាយបញ្ហា និងរៀបចំមាតុភូមិ-និវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៦នាក់** ដូចខាងក្រោម៖

- ស្ត្រីឈ្មោះ **អ.ស.ធ** អាយុ៣៣ឆ្នាំ មកពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បាននាំកូនប្រុសម្នាក់ អាយុ២ខែ ធ្វើដំណើរទៅម៉ាឡេស៊ីដោយខុសច្បាប់ នៅខែតុលា ឆ្នាំ២០១៦ ដើម្បីស្វែងរកស្វាមីដែលកំពុងធ្វើការនៅម៉ាឡេស៊ី ប៉ុន្តែរកពុំឃើញ។ បន្ទាប់ពីបានទទួលព័ត៌មានពីមន្ទីរពេទ្យមួយក្នុងរដ្ឋ Selangor ថាស្ត្រីរូបនេះធ្លាក់ខ្លួនឈឺ ខ្វះខាតថវិកា និងមិនមានអ្នកណាជួយ ស្ថានទូតបានចាត់មន្ត្រីទៅសួរសុខទុក្ខ និងបានធ្វើអន្តរាគមន៍ទៅមន្ទីរពេទ្យ ដើម្បីអោយនាងនិងកូនប្រុស រួចផុតពីការបង់ថ្លៃដល់មន្ទីរពេទ្យចំនួន៨០០០រីងហ្គីត (ប្រមាណ២០០០ដុល្លារអាមេរិក)។

ស្ថានទូតបានទទួលនាងនិងកូនប្រុស ឲ្យស្នាក់នៅ ចាប់ពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ហើយស្ថានទូតក៏បានបង់ពិន័យជូនការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី និងឧបត្ថម្ភសំបុត្រយន្តហោះជូននាងនិងកូនផងដែរ។

- ពលករឈ្មោះ **ហ.ក.ស** អាយុ២៤ឆ្នាំ មកពីស្រុកបវិល ខេត្តបាត់ដំបង បានទៅធ្វើការនៅទូកនេសាទថៃក្នុងដែនសមុទ្រម៉ាឡេស៊ី កាលពីឆ្នាំ២០១៥ ហើយមានទំនាស់ឈ្លោះវាយតប់គ្នាជាមួយថៅកែជនជាតិថៃ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦។ ពលករបានលោតចូលសមុទ្រ ហើយត្រូវបានអាជ្ញាធរម៉ាឡេស៊ី ជួយសង្គ្រោះនៅចុងខែកក្កដាឆ្នាំ២០១៦។ បន្ទាប់ពីបានទទួលព័ត៌មាននេះ ស្ថានទូតបានចាត់មន្ត្រីទៅទទួលពលករពីរដ្ឋ Terrenganu នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ មកស្នាក់នៅក្នុងស្ថានទូត។ ស្ថានទូតបានបង់ពិន័យជូនការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី និងឧបត្ថម្ភសំបុត្រយន្តហោះដល់ពលករ។

ស្ត្រីឈ្មោះ **អ.ស.ធ** និងកូន ព្រមទាំងពលករ **ហ.ក.ស** បានដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៥** ខែ**ធ្នូ** ឆ្នាំ **២០១៦** វេលាម៉ោង**០៧:៥០នាទីព្រឹក** តាមយន្តហោះលេខ AK536 ។

- ពលការិនី **ម.ច.ធ** អាយុ៣២ឆ្នាំ មកពីស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បានទៅម៉ាឡេស៊ី កាលពីខែមេសា ឆ្នាំ២០១៦ និងពលការិនី **ខ.យ** អាយុ២៤ឆ្នាំ មកពីស្រុកដំបែរ ខេត្តត្បូងឃ្មុំ បានទៅម៉ាឡេស៊ីនៅខែកញ្ញា ឆ្នាំ២០១៦ ហើយអ្នកទាំងពីរធ្វើការជាអ្នកបោសសំអាត តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក ពលការិនីទាំងពីរនាក់បានទៅស្ថានទូតនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

- ពលការិនី **ជ.ស.ល** អាយុ២៨ឆ្នាំ មកពីស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា ។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូត នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើសុំជួយឲ្យបានត្រឡប់ទៅកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ និយោជករបស់ពលការិនីទាំង**៣នាក់** បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ លិខិតឆ្លងដែន និងសំបុត្រយន្តហោះ ជូនដល់ពលការិនីទាំង៣នាក់។

ពលការិនីឈ្មោះ **ម.ច.ធ** ឈ្មោះ**ខ.យ** និងឈ្មោះ**ជ.ស.ល** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៩** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមយន្តហោះលេខ AK536 ។

**២**- ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ចិន** បានសម្របសម្រួលជាមួយប៉ូលីសទីក្រុងប៉េកាំង រៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរម្នាក់ ឈ្មោះ **ស.ម** អាយុ២៩ឆ្នាំ មកពីស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលបានស្ម័គ្រចិត្តធ្វើដំណើរទៅប្រទេសចិន កាលពីខែធ្នូ ឆ្នាំ២០១៣ និងបានរៀបការជាមួយបុរសជនជាតិចិន នៅខែមករា ឆ្នាំ២០១៤។ ដោយសាររស់នៅមិនចុះសំរុងជាមួយប្តី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ នាងបានស្នើសុំស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅដល់នាងអំឡុងពេលដោះស្រាយជាមួយប្តីនិងប៉ូលីសចិន ហើយអង្គការ IOM នៅទីក្រុងប៉េកាំង ជាអ្នកផ្តល់សំបុត្រយន្តហោះ ។

ស្ត្រីឈ្មោះ **ស.ម** បានត្រឡប់មកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** កាលពីថ្ងៃទី**២២** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង**២៣:៣០**នាទី តាមយន្តហោះលេខ CZ323 ៕

ភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ